សហគមន៍ខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ....................................ស.ខ.ក.ក.

# លិខិតរំលែកទុក្ខ

## ជូន លោកស្រី ម៉ុង សួន

ក្នុងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា សហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់មាន សេចក្តីរន្ធត់ និងទុក្ខយ៉ាងក្រៀមក្រំបំផុត នៅពេលដែលបានទទួលដំណឹងអកុសលថា លោកសុខ សាមី សមាជិកគាំទ្រដ៏សកម្មនៃសហគមន៍ខ្មែរកម្ពុជាក្រោម នៅទីក្រុង Long Beach រដ្ឋ California បានទទួល អនិច្ចកម្មកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ដោយជរាពាធ។

មរណភាពលោកសុខ សាមី គឺជាការបាត់នៃកុលបុត្រខ្មែរស្នេហាជាតិមួយរូបដ៏សំខាន់ ជាការបាត់ បង់ស្វាមី ជាការបាត់បង់ឪពុក ជាការបាត់បង់ជីតាដ៏ជាទីស្រឡាញ់ ដែលប្រកបដោយគុណធម៌ និងព្រហ្ម វិហារធម៌ដ៏ថ្លៃថ្លា។ សហគមន៍ខ្មែរកម្ពុជាក្រោម សូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុត ជា មួយក្រុមគ្រួសារនៃសព ជាមួយសមាគមខ្មែរកម្ពុជាក្រោម សមាគមខ្មែរកម្ពុជាក្រោម ព្រះសង្ឃ គណៈកម្ម ការ និងពុទ្ធបរិស័ទនៅទីក្រុង Long Beach រដ្ឋ California ដោយសេចក្តីសោកស្តាយ អាឡោះអាល័យ យ៉ាងក្រៃលែង។

លោកសុខ សាមី មិនថារស់នៅទីណា ជីវភាពលំបាកបែបណាទេ លោក បានរក្សាយ៉ាងខ្ជាប់ខ្ជួន នូវឧត្តមគតិស្នេហាជាតិដ៏បរិសុទ្ធ គួរជាទីគោរពបំផុត។ លោកបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុបំរើជាតិ និងសាសនា ជាពិសេសជាសមាជិកគាំទ្រសហគមន៍ខ្មែរកម្ពុជាក្រោមមួយរូបដ៏សំខាន់នៅរដ្ឋ California ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមវាយតម្លៃយ៉ាងខ្ពស់ ចំពោះវីរភាពស្នេហាជាតិ និងសាសនាដ៏មុះ មុតនេះ ហើយសហគមន៍ខ្មែរកម្ពុជាក្រោមចារិកឈ្មោះលោកសុខ សាមី ទុកក្នុងទំព័រប្រវត្តិសាស្ត្ររបស់ សហគមន៍ខ្មែរកម្ពុជាក្រោមតទៅជារៀងរហូត។

ដោយឥដ្ឋមនុញ្ញផលដែលកើតមានអំពីការបំរើជាតិ និងសាសនាដ៏ស្មោះត្រង់ សូមវិញ្ញាណក្ខន្ធ លោក សុខ សាមី បានទៅសោយសុខក្នុងសុគតិភពកុំបីខាន និងសូមប្រគេនពរ និងជូនពរព្រះករុណា គ្រប់ព្រះអង្គ ក្រុមគ្រួសារសព និងពុទ្ធបរិស័ទទាំងអស់ បានប្រកបទៅដោយពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២
នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

សហគមន៍ខ្មែរកម្ពុជាក្រោម THE KHMER KAMPUCHEA KROM COMMUNITY

ថាច់ សេដ្ឋា